កម្មវិធីអភិរក្ស និងប្រើប្រាស់ដោយនិរន្តរភាព
នូវជីវៈចម្រុះតំបន់ដីសើមទន្លេមេគង្គ
ការិយាល័យកម្មវិធីថ្នាក់ជាតិ
ផ្ទះលេខ៤៨ វិថីព្រះសីហនុ ជាន់ទី១ ក្រសួងបរិស្ថាន ប្រអប់សំបុត្រ ១៥០៤ ភ្នំពេញ
ទូរស័ព្ទ ++855 (0)23 222 311/2 ទូរសារ ++855 (0)23 211 944
Email: mekongwetlands@online.com.kh Website: www.mekongwetlands.org

សូមគោរពជូន

ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន

មេត្តាជ្រាប

តាមរយៈ ឯកឧត្តមអគ្គនាយកបច្ចេកទេសក្រសួងបរិស្ថាន និងជានាយកកម្មវិធីអភិរក្ស និងប្រើប្រាស់ដោយនិរន្តរភាពនូវជីវៈចម្រុះតំបន់ដីសើមទន្លេមេគង្គ (MWBP)។

# របាយការណ៍សង្ខេប

## កម្មវិធីអភិរក្ស និងប្រើប្រាស់ដោយនិរន្តរភាពនូវជីវៈចម្រុះតំបន់ដីសើមទន្លេមេគង្គ

### ១. ពត៌មានគន្លឹះពីកម្មវិធី

កម្មវិធីអភិរក្ស និងប្រើប្រាស់ដោយនិរន្តរភាពនូវជីវៈចម្រុះតំបន់ដីសើមទន្លេមេគង្គ (MWBP) ជាកម្មវិធីរួមប្រតិបត្តិដោយ កម្មវិធីអភិវឌ្ឍសហប្រជាជាតិ (UNDP) - អង្គការសហភាពអភិរក្សពិភពលោក (IUCN) - គណៈកម្មការទន្លេមេគង្គ (MRC) ដេលទទួលថវិកាពីមូលនិធិបរិស្ថានពិភពលោក (GEF) - ពីអង្គការសហភាពអភិរក្សពិភពលោក (IUCN) - ពីស្ថានទូតប្រទេសហូឡង់ ដោយធ្វើការជាមួយស្ថាប័នជំនាញនៃប្រទេសអាងទន្លេមេគង្គទាំង៤ កម្ពុជា ឡាវ ថៃ និងវៀតណាម។ កម្មវិធីចាប់ផ្តើមអនុវត្តជាផ្លូវការតាំងពីខែកក្កដា ឆ្នាំ២០០៤ រហូតដល់ឆ្នាំ២០០៩ ចែកជាពីរដំណាក់កាល ដែលដំណាក់កាលទី១ (កក្កដា ២០០៤ - ធ្នូ ២០០៦) និងដំណាក់កាលទី២ (២០០៧-២០០៩) ដែលមានថវិកាសរុបទាំងអស់ប្រមាណជា៣០លានដុល្លាសហរដ្ឋអាមេរិច។

**ទិសដៅ:** ការអភិរក្ស និងប្រើប្រាស់ប្រកបដោយនិរន្តរភាពនូវជីវៈចម្រុះតំបន់ដីសើមក្នុងអាងទន្លេមេគង្គភាគខាងក្រោម។
**គោលបំណង:** ពង្រឹងសមត្ថភាពថ្នាក់តំបន់ ថ្នាក់ជាតិ និងសមត្ថភាពមូលដ្ឋានដើម្បីអភិរក្ស និងប្រើប្រាស់ប្រកបដោយនិរន្តរភាពជីវៈចម្រុះតំបន់ដីសើមក្នុងអាងទន្លេមេគង្គភាគខាងក្រោម។

## ២. យុទ្ធសាស្ត្ររបស់កម្មវិធី

- ធ្វើការជាដៃគូជាមួយស្ថាប័ន ឬអង្គការដែលមានសកម្មភាពពាក់ព័ន្ធស្រាប់ ដើម្បីពង្រឹងសមត្ថភាពនិងការទទួលខុសត្រូវរបស់សាម៉ីអង្គភាពដែលពាក់ព័ន្ធនឹងការប្រើប្រាស់ គ្រប់គ្រង និង/រឺសំរបសំរួលលើតំបន់ដីសើម។
- ធ្វើឱ្យប្រសើរឡើងពីទំនាក់ទំនង ការអប់រំ និងផ្សព្វផ្សាយសាធារណៈអំពីតំបន់ដីសើម សារៈសំខាន់ និងបញ្ហាដែលកើតមាននានា។ ក្នុងការអប់រំនេះ ជារួមធ្វើឡើងជាវគ្គខ្លីៗដែលរៀបចំនៅថ្នាក់តំបន់ តាមប្រទេស និងតាមតំបន់បង្ហាញគំរូដែលមានអាទិភាពតាមលំដាប់ គឺបុគ្គលិកកម្មវិធី ដៃគូផ្ទាល់ (ក្រសួងបរិស្ថាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងធនធានទឹក និងឧតុនិយម និងគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា) និងបន្ទាប់ទៀតលើអាជ្ញាធរមូលដ្ឋាន សហគមន៍ ប្រជាជន និងស្ថាប័នពាក់ព័ន្ធផ្សេងៗទៀត។
- ពិនិត្យមើលលើគោលនយោបាយជាតិ-គោលនយោបាយតាមវិស័យដែលនាំឱ្យមានផលប៉ះពាល់ដល់ការអភិរក្ស និងប្រើប្រាស់ដោយនិរន្តភាពតំបន់ដីសើម ព្រមទាំងផ្តល់អនុសាសន៍ដល់គោលនយោបាយទាំងនេះអំពីកង្វះខាត អំពីការជាន់តួនាទី-ភារកិច្ច ការគ្រប់គ្រង និងការសំរបសំរួលជាដើម។
- ពិនិត្យឡើងវិញនិងផ្តល់អនុសាសន៍លើពង្រាងផែនការសកម្មភាពតំបន់ដីសើមជាតិដែលបានព្រៀងតាំងពីឆ្នាំ១៩៩៩មកម្ល៉េះ និងការអនុវត្តន៍ ព្រមទាំងសមត្ថភាពក្នុងការអនុវត្តន៍កាតព្វកិច្ចនៃកិច្ចព្រមព្រៀងពហុភាគីស្តីពីបរិស្ថាន។ ការងារនេះ មានទំនាក់ទំនងផ្ទាល់ជាមួយការពិនិត្យឡើងវិញនូវគោលនយោបាយខាងលើ ដែលជាដំណើរជួយបំពេញគ្នាទៅវិញទៅមក។ តាមរយៈការពិនិត្យមើលដំណើរការនេះ គឺជាមេរៀនកន្លងមកពាក់ព័ន្ធនឹងការគ្រប់គ្រង ក៏ដូចជាសិក្សាពីយន្តការ និងនីតិវិធីក្នុងការជំរុញការអនុវត្តន៍អនុសាសន៍គោលនយោបាយ និងកាតព្វកិច្ចនៃកិច្ចព្រមព្រៀងពហុភាគីស្តីពីបរិស្ថាន។
- ការប្រមូល និងចងក្រងពតិមានស្តីពីតំបន់ដីសើមក្នុងប្រទេសកម្ពុជា តាមរយៈការធ្វើសារពើភ័ណ្ឌតំបន់ដីសើមទូទៅក្នុងប្រទេស ដើម្បីជាមូលដ្ឋានគ្រឹះក្នុងការយល់ដឹងពីតំបន់ដីសើម ប្រព័ន្ធ និងប្រព័ន្ធរងតំបន់ដីសើម និងការធ្វើសារពើភ័ណ្ឌលំអិតតាមតំបន់សំខាន់ៗមួយចំនួន។ តាមរយៈពតិមាននេះនឹងបង្ហាញពីស្ថានភាពតំបន់ដីសើមរបស់ប្រទេស ក៏ដូចជាមូលដ្ឋានទិន្នន័យគោល សំរាប់ជាប្រយោជន៍ក្នុងការត្រួតពិនិត្យ វាយតំលៃ ឬរាយការណ៍ពីសភាពតំបន់ដីសើមនេះ។
- ការរៀបចំតំបន់បង្ហាញគំរូតំបន់បង្ហាញរ៉ាមសារ-ស្ទឹងត្រែង ពីការគ្រប់គ្រងតាមបែបសមាហរណកម្មដោយការអភិរក្ស និងប្រើប្រាស់ដោយនិរន្តភាព។ នេះជាការរៀបចំនូវយន្តការមូលដ្ឋានក្នុងការអភិរក្ស និងប្រើប្រាស់ដោយនិរន្តរភាពតំបន់ដីសើម ដែលប្រើប្រាស់ជារបៀបក្នុងការគ្រប់គ្រងសមាហរណកម្ម។ វិធីសាស្ត្រនេះ មាន៣សមាសធាតុ គឺ (១) ការទំនាក់ទំនង អប់រំ ផ្សព្វផ្សាយសាធារណៈ (២) ការសិក្សានិងគ្រប់គ្រងលើជីវៈចម្រុះ និង (៣) ការសិក្សានិងលើកស្ទួយជីវភាពរស់នៅរបស់ប្រជាជនក្នុងមូលដ្ឋាន ។ ជាគោលគឺ ការរៀបចំផែនការគ្រប់គ្រងតំបន់រ៉ាមសារ-ស្ទឹងត្រែង ការរៀបចំការគ្រប់គ្រងធនធានធម្មជាតិជាសហគមន៍ ព្រមទាំងការសាកល្បងលើការអនុវត្តន៍ផែនការគ្រប់គ្រងនេះ។

## ៣. ការរីកចំរើន

- កម្មវិធីអភិរក្សជីវៈចម្រុះបានរៀបចំ និងបង្កើតដៃគូជាមួយស្ថាប័ន និងអង្គការមិនមែនរដ្ឋាភិបាលនានាដូចជាៈ
    - ១) ស្ថាប័នជាតិ មានកិច្ចសហប្រតិបត្តិការនិងការធ្វើការជាប្រព័ន្ធជាមួយគ្នា តាមរយៈការរៀបចំគណៈកម្មាធិការដឹកនាំកម្មវិធី គណៈគ្រប់គ្រងគំរោងខេត្ត ការកសាងសមត្ថភាព និងការទំនាក់ទំនងជាមួយបណ្តាញអន្តរជាតិ បណ្តាសហគមន៍អ្នកផ្តល់ជំនួយ និងលេខាធិការដ្ឋាននៃអនុសញ្ញាអន្តរជាតិសំខាន់ៗនានាដូចជា CBD និង

Ramsar ជាដើម។ ជាពិសេសកម្មវិធីបានចូលរួមសហការផ្ទាល់ ដើម្បីជួយក្នុងការអភិរក្សនិងប្រើប្រាស់ដោយនិរន្តភាពលើស្ថាប័នសំខាន់៤ គឺ ក្រសួងបរិស្ថាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងធនធានទឹក និងឧតុនិយម និងគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា។

២) សមាគមថែរក្សាបរិស្ថាន និងវប្បធម៌ (CEPA): បានទទួលថវិកាពីកម្មវិធីអភិរក្ស និងការប្រើប្រាស់ដោយនិរន្តរភាពនូវជីវៈចម្រុះតំបន់ដីសើមទន្លេមេគង្គ មានឈ្មោះថា គំរោងសាលាភូមិ ដែលបានធ្វើការរៀបចំសហគមន៍នៅតំបន់រ៉ាមសារ-ស្ទឹងត្រែង និងដឹកនាំសហគមន៍នេះ ដើម្បីសិក្សាស្រាវជ្រាវពីលក្ខណៈអេកូឡូស៊ី និងពីការប្រើប្រាស់លើធនធានទាំងនេះ សំរាប់ជាប្រយោជន៍ក្នុងការធ្វើផែនការគ្រប់គ្រង និងត្រួតពិនិត្យលើធនធានរបស់គាត់។

៣) អង្គការសុខភាពគ្មានព្រំដែន (Health Unlimited): ក៏បានទទួលថវិកាពីកម្មវិធី MWBP ដែរ ដើម្បីជួយសិក្សាស្រាវជ្រាវពីបញ្ហាសុខភាព ដែលកើតមានលើប្រជាជននៅតំបន់រ៉ាមសារ-ស្ទឹងត្រែង និងសំរបសំរួលអន្តាគមន៍លើបញ្ហានានា រួមទាំងការផ្សព្វផ្សាយនិងការធ្វើអនាម័យជារួមផងដែរ។

៤) មជ្ឈមណ្ឌលសិក្សា និងអភិវឌ្ឍន៍កសិកម្មកម្ពុជា (CEDAC): កសាងក្រុមការងារកិច្ចការទឹក និងរៀបចំពិនិត្យគោលនយោបាយតំបន់ដីសើម និងធ្វើការសិក្សាពីការធ្វើកសិកម្មនៅតំបន់រ៉ាមសារ ដោយផ្តល់ជំរើសដល់ការធ្វើកសិកម្មនេះ។

៥) អង្គការ (WCS): ធ្វើការសិក្សានិងស្រាវជ្រាវពីស្ថានភាពជីវៈចម្រុះនៅតំបន់រ៉ាមសារស្ទឹងត្រែង និងសក្តានុពលភាពសំរាប់ធ្វើការសិក្សាពីក្រពើត្រីនៅប្រទេសកម្ពុជា។

៦) អង្គការមូលនិធិសំរាប់សត្វព្រៃ និងធម្មជាតិ (WWF): ធ្វើការសិក្សាស្វែងយល់ពីស្ថានភាពសត្វផ្សោតព្រមទាំងរៀបចំផែនការសកម្មភាពអភិរក្ស និងជួយសំរបសំរួលការងារពាក់ព័ន្ធលើប្រភេទនេះ។

៧) អង្គការ (FFI): ធ្វើការសិក្សាស្វែងយល់ពីស្ថានភាពសត្វក្រពើត្រី ព្រមទាំងរៀបចំផែនការសកម្មភាពអភិរក្ស និងជួយសំរបសំរួលការងារពាក់ព័ន្ធលើប្រភេទនេះ។

៨) អង្គការមូលនិធិសត្វក្រៀលអន្តរជាតិ ICF: ធ្វើការសិក្សាស្វែងយល់ពីស្ថានភាពសត្វក្រៀលនិង សត្វស្លាបទឹក ព្រមទាំងរៀបចំផែនការសកម្មភាពអភិរក្ស និងជួយសំរបសំរួលការងារពាក់ព័ន្ធលើប្រភេទនេះ។

៩) អង្គការ TRAFFIC: សិក្សា និងស្រាវជ្រាវពីការធ្វើអាជីវកម្មសត្វព្រៃក្នុងខេត្តស្ទឹងត្រែង។

១០) សមាគមក្រុមសិល្បៈសុវណ្ណភូមិ: ការអប់រំប្រជាប្រិយតាមការសំដែងពីការអភិរក្ស និងការអភិវឌ្ឍន៍។

១១) អង្គការម្លប់បៃតង Mlup Baitong: ចូលរួមក្នុងការជួយផ្សព្វផ្សាយពីការអភិរក្សនិងប្រើប្រាស់ដោយនិរន្តភាពតំបន់ដីសើម តាមរយៈវិទ្យុនិងការរៀបចំព្រឹត្តិការណ៍ជាដើម។

១២) វិទ្យាស្ថានអន្តរជាតិគ្រប់គ្រងទឹក (IWMI): សិក្សាស្រាវជ្រាវពីប្រព័ន្ធស្រោចស្រព និងការគ្រប់គ្រងតំបន់ដីសើមនៅខេត្តកណ្តាល និងស្ទឹងត្រែង ព្រមទាំងសិក្សាពីមុខងារនិងតម្លៃតំបន់ដីសើម។ ជាពិសេសបំផុតនោះគឺការរៀបចំសិក្សានិងធ្វើសារពើភ័ណតំបន់ដីសើមប្រទេសកម្ពុជាដែលរួមមានទាំងចំណាត់ថ្នាក់តំបន់ដីសើម ផែនទី ព្រមទាំងពីប្រព័ន្ធ និងប្រព័ន្ធរងរបស់វា។

១៣) កម្មវិធីទឹកនិងធម្មជាតិ WANI: ជាកម្មវិធីមួយរបស់អង្គការសហភាពអភិរក្សពិភពលោក ធ្វើការចងក្រងនិងបង្កើតក្រុមកិច្ចការទឹក ដើម្បីពិគ្រោះពិភាក្សាពីបញ្ហាផ្សេងៗពាក់ព័ន្ធនឹងទឹក ព្រមទាំងរៀបចំការបកប្រែ និងបោះពុម្ពឯកសារពីលំហូរបរិស្ថាន។

១៤) វិទ្យាស្ថានសិក្សាពីការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួម (CBNRM-LI)៖ការរៀបចំសិក្សាលើគោលនយោបាយព្រៃឈើដែលជាហេតុបង្កឱ្យមានការប៉ះពាល់ដល់ការអភិរក្ស និងប្រើប្រាស់ដោយនិរន្តរភាពតំបន់ដីសើមក្នុងប្រទេសកម្ពុជា។

១៥) មជ្ឈមណ្ឌលត្រីពិភពលោក (World Fish Centre) និងសម្ព័ន្ធភាពតំបន់ដីសើម (Wetland Alliance)៖ ការរៀបចំសិក្សាលើគោលនយោបាយវិស័យជលផលដែលជាហេតុបង្កឱ្យមានការប៉ះពាល់ដល់ ការអភិរក្ស និងប្រើប្រាស់ដោយនិរន្តភាពតំបន់ដីសើមក្នុងប្រទេសកម្ពុជា។

- ការកសាងសមត្ថភាព និងអប់រំផ្សព្វផ្សាយពីតំបន់ដីសើម ពីសារៈសំខាន់ និងបញ្ហាប្រឈមនានា៖ បានផ្តល់វគ្គសិក្សាសំរាប់បុគ្គលិកជាតិចំនួន ៣៣នាក់ (ដែលក្នុងនោះ មកពីអង្គការមិនមែនរដ្ឋភិបាលចំនួន ៥នាក់) ទៅលើប្រធានបទចំនួន ១២ នៅតាមទីតាំងផ្សេងៗគ្នាក្នុងតំបន់។ រីឯការផ្សព្វផ្សាយគឺមានភាពទូលំទូលាយសំរាប់សាធារណៈជនដែលរួមមាននិស្សិតតាមសកលវិទ្យាល័យនានាប្រមាណ៥០០នាក់ តាមរយៈការផ្តល់មេរៀនផ្ទាល់។ ក្រៅពីនេះគឺ ការចូលរួមរាប់ពាន់នាក់ក្នុងប្រទេស សំរាប់ព្រឹត្តិការណ៍ដូចជាទិវាតំបន់ដីសើមពិភពលោក ជាងនេះទៅទៀត ការផ្សព្វផ្សាយតាមរយៈសារពត៌មាន ព្រឹត្តិប័ត្រ ការធ្វើសំភាសន៍តាមកញ្ចក់ទូរទស្សន៍ និងប្រព័ន្ធវិទ្យុក្នុងប្រទេស និងក្រៅប្រទេស និងការសំដែងសិល្បៈប្រជាប្រិយពីការអភិរក្សនិងប្រើប្រាស់តំបន់ដីសើម។ ចាប់តាំងពីឆ្នាំ ២០០៥ រហូតមកទល់ពេលនេះ បើពិនិត្យទៅលើសារពត៌មាន ឃើញមានប្រមាណ២០០អត្ថបទដែលនិយាយពាក់ព័ន្ធពីតំបន់ដីសើម ក្នុងនោះប្រមាណជា២០%ពាក់ព័ន្ធផ្ទាល់ជាមួយកម្មវិធី MWBP។ អ្វីដែលមានជាសមិទ្ធផលទាំងការអប់រំ និងផ្សព្វផ្សាយមិនទាន់ជាការគ្រប់គ្រាន់ក្នុងការជួយគាំទ្រ និងការពារតំបន់ដីសើមជាតិនៅឡើយទេ តែដំណើរការនេះកំពុងតែពង្រឹង និងពង្រីកឱ្យកាន់តែមានប្រសិទ្ធភាពថែមទៀត។
- ចំណែកឯការងារពិនិត្យលើគោលនយោបាយ ផែនការជាតិតំបន់ដីសើម និងកិច្ចព្រមព្រៀងពហុភាគីស្តីពីបរិស្ថាន ក៏ដូចជាការរៀបចំធ្វើសារពើភ័ណ្ឌតំបន់ដីសើម កំពុងតែដំណើរទៅយ៉ាងរលូនក្រោមកិច្ចសហប្រតិបត្តិការជាមួយដៃគូផ្សេងៗដូចបានរៀបរាប់ខាងលើនេះ ហើយកិច្ចការទាំងនេះនឹងត្រូវបញ្ចប់ជារួមនៅមុនដំណាច់ឆ្នាំ ២០០៦នេះ។
- តំបន់បង្ហាញរ៉ាមសារ-ស្ទឹងត្រែង ពាក់ព័ន្ធនឹងការរៀបចំផែនការគ្រប់គ្រងតំបន់តាមបែបសមាហរណកម្មពីការអភិរក្សនិងការប្រើប្រាស់ប្រកបដោយនិរន្តភាពតំបន់ដីសើម គឺបាននឹងកំពុងដំណើរការរួមទាំងការកំណត់តំបន់អភិរក្ស និងការសាកល្បងលើកស្ទួយជីវភាពប្រជាជនតាមបែបផែននិរន្តភាព។

## ៤. បញ្ហា និងការលំបាក

១) វិសាលភាពរបស់តំបន់ដីសើមមានភាពទូលំទូលាយ ដែលជាហេតុធ្វើឱ្យប៉ះពាល់ដែនសមត្ថកិច្ចរបស់ក្រសួង និងស្ថាប័នដទៃទៀត។

២) ការប្រឈមនិងតំរូវការអភិវឌ្ឍន៍ប្រទេស តាមរយៈការកែប្រែតំបន់ដីសើមទៅជាទីក្រុង រោងចក្រ សហគ្រាស និងតំបន់ឧស្សាហកម្មនានា និងតំរូវការអភិវឌ្ឍន៍ និងវិនិយោគលើតំបន់ទាំងនេះ។

៣) កង្វះខាងគោលនយោបាយ និងយន្តការច្បាស់លាស់ដើម្បីសំរបសំរួល ក៏ដូចជាគ្រប់គ្រងតំបន់ដីសើម។ ការយកចិត្តទុកដាក់ និង គ្រប់គ្រងថែរក្សាតំបន់ដីសើមរបស់ជាតិនៅមានកំរិតទាប មានន័យថាពុំមែនជាវិស័យ

អាទិភាពសំរាប់ប្រទេស និងជាពិសេសពុំមានថវិការក្នុងការធ្វើអន្តរាគមន៍លើការគ្រប់គ្រង ក៏ដូចជាសំរបសំរួលដល់តំបន់ដីសើមផងដែរ ។

(៤) កង្វះចំណេះដឹង និងធនធានមនុស្សក្នុងការចូលរួមធ្វើការងារនេះ ជាពិសេសការចូលរួមនិងគាំទ្រពីស្ថាប័នពាក់ព័ន្ធ។

## ៥. សន្និដ្ឋាន និងសំណូមពរ

ទោះបីជាមានការខិតខំប្រឹងប្រែងជួយពីកម្មវិធីអភិរក្ស និងប្រើប្រាស់ដោយនិរន្តរភាពនូវជីវៈចម្រុះតំបន់ដីសើមទន្លេមេគង្គ (MWBP) ប៉ុណ្ណាក៏ដោយ ក៏ការចូលរួម និងគាំទ្រពីស្ថាប័នជាតិនានា នៅមានកំរិតនៅឡើយ ចំពោះការគ្រប់គ្រង និងថែរក្សាតំបន់ដីសើមនេះ ។ ភាពជោគជ័យក្នុងថែរក្សាតំបន់ដីសើមជាតិ គឺជាកិច្ចសហប្រតិបត្តិ និងជំរុញជារួមសំរាប់គ្រប់ស្ថាប័ន និងអ្នកពាក់ព័ន្ធយកចិត្តទុកដាក់ និងដាក់បញ្ចូលក្នុងកម្មវិធីរៀង១ខ្លួនតាមសាមីស្ថាប័ន ដើម្បីធ្វើយ៉ាងណាកុំឱ្យបាត់បង់តំបន់ដីសើម តួនាទី និងផលិតភាពរបស់វា ។

យោងតាមបញ្ហា និងភាពលំបាកកើតមានដូចខាងលើ សូមគោរពជូនឯកឧត្តមមេត្តាពិនិត្យនិងផ្តល់អនុសាសន៍ដើម្បី ជាប្រយោជន៍ដល់ការសំរបសំរួល និងគ្រប់គ្រងថែរក្សាតំបន់ដីសើមជាតិអោយបានស្ថិតស្ថេរគង់វង្សសំរាប់បរិស្ថានជាតិ និងកូនចៅជំនាន់ក្រោយ ។

សូមឯកឧត្តមមេត្តាជ្រាប និងជួយផ្តល់អនុសាសន៍ដោយអនុគ្រោះ ។
សូមឯកឧត្តមមេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។

ភ្នំពេញថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៦
**រាយការណ៍ដោយ**

**សុខ ទង់**
**ប្រធានសំរបសំរួលកម្មវិធី**

**បានឃើញ និងឯកភាព**

**ឡុញ ឃារីល**
នាយកកម្មវិធីជាតិ

**ចំលងជូន:**

- ឯកឧត្តម **តាន់ វុឌ្ឍា**
- លេខាធិការដ្ឋានអគ្គនាយកបច្ចេកទេស
- នាយកដ្ឋានការពារអភិរក្សធម្មជាតិ